**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តឧត្តរមានជ័យ**

សំណុំរឿងរដ្ឋប្បវេណីលេខ: ០៧៥
ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣
សាលក្រមលេខ៖ ២២(ក)/៣៤
ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តឧត្តរមានជ័យ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៤
នៅសាលជម្រះក្តី នៃសាលាដំបូងខេត្តឧត្តរមានជ័យ ។

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ជាប្រធាន និងជាចៅក្រម នៃសាលាដំបូងខេត្តឧត្តរមានជ័យ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តឧត្តរមានជ័យ

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ លើសំណុំរឿងរដ្ឋប្បវេណីលេខ: ០៧៥ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ដែលមានគូវិវាទរវាង៖

-ដើមចោទឈ្មោះ [redacted] ចំប៉ី ភេទស្រី អាយុ៤៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ធ្វើស្រែ អាសយដ្ឋានបច្ចុប្បន្ននៅ [redacted] ។

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

-ចុងចម្លើយឈ្មោះ [redacted] ឌីណា ភេទស្រី អាយុ៤៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ លក់ឡេ អាសយដ្ឋានបច្ចុប្បន្ននៅភូមិ [redacted] ។

## I.អង្គហេតុ និងការអះអាងរបស់គូភាគី៖

១/ ខ្លឹមសារសាលក្រមដែលដើមចោទទាមទារ៖

១.១/ បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ឌីណា សងប្រាក់ចំនួន ៤,៥០០ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិក ទៅឲ្យដើមចោទវិញ ។

១.២/ ប្តឹងទាមទារសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាពីចុងចម្លើយចំនួន ២,០០០ ដុល្លារអាមេរិក ។

១.៣/ ប្តឹងសុំឲ្យតុលាការអនុវត្តសាលក្រមជាបណ្តោះអាសន្ន នៅចំណុចទី១ ខាងលើ ។

១.៤/ ប្តឹងសុំឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកលើសោហ៊ុយ និងប្រាក់ប្រដាប់ក្តីផ្សេងៗ ។

២/ ការពន្យល់ត្រួសៗអំពីរឿងក្តី៖

កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ ចុងចម្លើយឈ្មោះ [redacted] ឌីណា បានមកខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] ចំប៉ី ចំនួន ៤,៥០០ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិក ដោយចុងចម្លើយឈ្មោះ [redacted] ឌីណា សន្យាថា ០២សប្តាហ៍ទៀត គាត់នឹងសងដើមចោទឈ្មោះ [redacted] ចំប៉ី វិញ ហើយដើមចោទក៏ព្រមឲ្យចុងចម្លើយឈ្មោះ [redacted] ឌីណា ខ្ចីប្រាក់ និងឲ្យប្រាក់ចំនួន ៤,៥០០



Scanned with CamScanner

(បួនពាន់ប្រាំរយ) ដុល្លារអាមេរិកតែម្តង ។ បន្ទាប់មកបានចំនួន ០២សប្តាហ៍ក្រោយមក ដើមចោទក៏ទៅទាមទារប្រាក់ដែលជំពាក់ ហើយចុងចម្លើយឈ្មោះ [redacted] ឌីណា ប្រាប់ដើមចោទវិញថា មិនមានប្រាក់សងនោះទេ ចង់ប្តឹងឯណាក៏ប្តឹងទៅគេមិនខ្លាចទេ ។ ដើមចោទបានទាមទារប្រាក់ពីចុងចម្លើយឈ្មោះ [redacted] ឌីណា ឱ្យចូលខ្លួនមកសម្របសម្រួល និងដោះស្រាយជាមួយដែរ ប៉ុន្តែចុងចម្លើយឈ្មោះ [redacted] ឌីណា មិនព្រមចូលមកដោះស្រាយនោះទេ ហើយចុងចម្លើយឈ្មោះ [redacted] ឌីណា បានធ្វើការគេចវេស និងមិនគោរពទៅតាមការសន្យារបស់គេនោះទេ ហើយទង្វើនេះធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ដើមចោទយ៉ាងធ្ងន់ធ្ងរ ។

**៣/ សេចក្តីថ្លែងការណ៍របស់គូភាគី៖**

**ក-សេចក្តីថ្លែងការណ៍របស់ដើមចោទ៖**

-មេធាវីតំណាងឱ្យដើមចោទឈ្មោះ [redacted] បានថ្លែងការណ៍ថា: ខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ចំប៊ី សូមរក្សាការទាមទារដូចនៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ និងសេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួន នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ នៅដដែលដោយមិនមានការកែប្រែនោះទេ ។ កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ ចុងចម្លើយឈ្មោះ [redacted] ឌីណា បានមកខ្ចីប្រាក់ពីកូនក្តីខ្លួនចំនួន ៤,៥០០ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិក ដោយឈ្មោះ [redacted] ឌីណា សន្យាថា ០២សប្តាហ៍ទៀត គាត់នឹងសងកូនក្តីខ្លួនវិញ ហើយកូនក្តីខ្លួនក៏ព្រមឱ្យឈ្មោះ [redacted] ឌីណា ខ្ចីប្រាក់ និងឱ្យប្រាក់ចំនួន ៤,៥០០ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិកតែម្តង ។ បន្ទាប់មកបានចំនួន ០២សប្តាហ៍ក្រោយមក កូនក្តីខ្លួនក៏ទៅទាមទារប្រាក់ដែលជំពាក់ ហើយឈ្មោះ [redacted] ឌីណា ប្រាប់ថាកូនក្តីខ្លួនវិញថា មិនមានប្រាក់សងនោះទេ ចង់ប្តឹងឯណាក៏ប្តឹងទៅគេមិនខ្លាចទេ ។ កូនក្តីខ្លួនបានទាមទារប្រាក់ពីឈ្មោះ [redacted] ឌីណា ឱ្យចូលខ្លួនមកសម្របសម្រួល និងដោះស្រាយជាមួយដែរ ប៉ុន្តែឈ្មោះ [redacted] ឌីណា មិនព្រមចូលមកដោះស្រាយនោះទេ ហើយឈ្មោះ [redacted] ឌីណា បានធ្វើការគេចវេស និងមិនគោរពទៅតាមការសន្យារបស់គេនោះទេ ហើយទង្វើនេះធ្វើឱ្យប៉ះពាល់ផលប្រយោជន៍កូនក្តីខ្លួនយ៉ាងធ្ងន់ធ្ងរ ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីតំណាងឱ្យដើមចោទឈ្មោះ [redacted] ចំប៊ី ស្នើសុំឱ្យតុលាការចេញសាលក្រម និងសម្រេចតាមការទាមទារដូចជា៖

១.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ឌីណា សងប្រាក់ចំនួន ៤,៥០០ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិក ទៅឱ្យដើមចោទវិញ ។

២.ប្តឹងទាមទារសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាពីចុងចម្លើយចំនួន ២,០០០ ដុល្លារអាមេរិក ។

៣.ប្តឹងសុំឱ្យតុលាការអនុវត្តសាលក្រមជាបណ្តោះអាសន្ននៅចំណុចទី១ ខាងលើ ។

៤.ប្តឹងសុំឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកលើសោហ៊ុយ និងប្រាក់ប្រដាប់ក្តីផ្សេងៗ ។

**ខ-សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ៖**

-ចុងចម្លើយឈ្មោះ [redacted] ឌីណា បានថ្លែងការណ៍ថា: **អវត្តមាន** ។ ក្រឡាបញ្ជីបានធ្វើការបញ្ជូនដីកាកោះតាមនីតិវិធីនៃការបញ្ជូន ទៅទីលំនៅរបស់ចុងចម្លើយឈ្មោះ [redacted] ឌីណា ហើយចុងចម្លើយក៏បានផ្តិតមេដៃទទួលដីកាកោះនេះ និងលើរបាយការណ៍នៃការបញ្ជូន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីចូលរួមក្នុងនីតិវិធីការទាញហេតុផលផ្ទាល់មាត់ផងដែរ ។ តែដល់ថ្ងៃកំណត់ ចុងចម្លើយឈ្មោះ [redacted] ឌីណា មិនបានចូលរួមតាមការកោះហៅឡើយ ហើយក៏មិនបានធ្វើការជូនដំណឹងមកតុលាការ អំពីការអវត្តមាននេះផងដែរ ។

៤/ ចំណុចវិវាទ៖

-ចុងចម្លើយ មិនឯកភាពសងសំណងជម្ងឺចិត្តចំនួន ២,០០០ ដុល្លារអាមេរិក ដែលដើមចោទទាមទារ ។

៥/ ចំណុចគ្មានវិវាទ៖

-ចុងចម្លើយបានទទួលស្គាល់ថា ខ្លួនពិតជាបានជំពាក់ដើមចោទចំនួន ៤,៥០០ ដុល្លារអាមេរិក ពិតប្រាកដមែន ។

-ក្រោយពីបានឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការរបស់គូភាគី

-ក្រោយពីបានពិនិត្យភស្តុតាង នាពេលទាញហេតុផលដោយផ្ទាល់មាត់

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ ។

## III.សំអាងហេតុ

-តាមលទ្ធផលនៃការសាកសួរ និងពិនិត្យភស្តុតាង ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

១/ ទទួលស្គាល់ពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] ចំប៉ី ភេទស្រី អាយុ៤៣ឆ្នាំ សញ្ជាតិខ្មែរ ដោយមានលោក [redacted] ឈាងហេង ជាមេធាវីតំណាងដោយអាណត្តិ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២/ ផ្អែកតាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងឱ្យដើមចោទ [redacted] ចំប៉ី ឃើញថា: មេធាវីតំណាងឱ្យដើមចោទបានអះអាងថា កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ ចុងចម្លើយឈ្មោះ [redacted] ឌីណា បានមកខ្ចីប្រាក់ពីដើមចោទ ចំនួន ៤,៥០០ ដុល្លារអាមេរិក ដោយសន្យាថា ២សប្តាហ៍ក្រោយ នឹងសងមកវិញ តែក្រោយមកចុងចម្លើយមិនបានយកប្រាក់មកសងឱ្យដើមចោទវិញនោះទេ ។

៣/ ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] ឌីណា ឃើញថា: តុលាការបានធ្វើការកោះហៅចុងចម្លើយខាងលើ ត្រឹមត្រូវតាមនីតិវិធីនៃការបញ្ជូន ដើម្បីឱ្យចុងចម្លើយចូលរួមក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៤ ហើយចុងចម្លើយក៏បានផ្តិតមេដៃទទួលដីកាកោះនេះផងដែរ ។ តែដល់ថ្ងៃកំណត់ចុងចម្លើយមិនព្រមចូលខ្លួនមកតុលាការតាមការកំណត់ដោយគ្មានមូលហេតុ ដូច្នេះយោងតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការអាចធ្វើការជំនុំជម្រះបានដោយកំបាំងមុខចុងចម្លើយ និងចាត់ទុកថាចុងចម្លើយបានសារភាពទៅនឹងអង្គហេតុដែលលើកឡើងដោយដើមចោទ ។

៤/ ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ឃើញថា: ដើមចោទបានការទាមទារប្រាក់ ពីចុងចម្លើយចំនួន ៤,៥០០ ដុល្លារអាមេរិក ចំពោះការទាមទារនេះ តុលាការយល់ឃើញថា: តាមការសេចក្តីថ្លែងការណ៍របស់ចុងចម្លើយនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ ឃើញថា: ចុងចម្លើយបានទទួលស្គាល់ថាខ្លួនពិតជាបានជំពាក់ប្រាក់ដើមចោទចំនួន ៤,៥០០ ដុល្លារអាមេរិក ពិតប្រាកដមែន ដូច្នេះគប្បីតុលាការសម្រេចបង្គាប់ចុងចម្លើយសងប្រាក់ដែលជំពាក់នេះ ទៅដើមចោទវិញ ។

៥/ ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ឃើញថា: ដើមចោទបានទាមទារសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាពីចុងចម្លើយចំនួន ២,០០០ ដុល្លារអាមេរិក តែចុងចម្លើយមិនឯកភាពសងនោះទេ ចំពោះការទាមទារនេះ គប្បីតុលាការពិចារណាសម្រេចបង្គាប់ឱ្យចុងចម្លើយសងសំណងនេះ តាមព្យសនកម្មដែលបានកើតឡើងជាក់ស្តែងឱ្យបានសមរម្យ ។



Scanned with CamScanner

៦/ យល់ឃើញថា: ដើមចោទប្តឹងសុំឱ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្ន លើប្រាក់ដើមចំនួន ៤,៥០០ ដុល្លារអាមេរិក តុលាការយល់ឃើញថា: ការស្នើសុំនេះ មានមូលដ្ឋានសមរម្យ និងមានភាពច្បាស់លាស់ ម្យ៉ាងទៀតចុងចម្លើយក៏បានទទួលស្គាល់ថា ជំពាក់ប្រាក់ដើមចោទចំនួន ៤,៥០០ ដុល្លារអាមេរិក ផងដែរ ហើយប្រសិនបើមិនអនុញ្ញាតឱ្យមានការអនុវត្តបណ្តោះអាសន្ននោះទេ អាចធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់ដើមចោទកាន់តែធ្ងន់ធ្ងរ ទម្រាំតែសាលក្រមចូលជាស្ថាពរ ដូច្នេះគប្បីតុលាការសម្រេចប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន តាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅលើប្រាក់ដើមដែលចុងចម្លើយបានជំពាក់ ។

៧/ ផ្អែកតាមមាត្រា ៦៤ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី "ប្រាក់ប្រដាប់ក្តី" គឺជាបន្ទុករបស់ភាគីចាញ់ក្តី ។

## ៣-សេចក្តីសម្រេចបញ្ចប់

១/ ទទួលស្គាល់ពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] ចំប៉ី ភេទស្រី អាយុ៤៣ឆ្នាំ សញ្ជាតិខ្មែរ ដោយមានលោក [redacted]ឈាងហេង ជាមេធាវីតំណាងដោយអាណត្តិ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២/ បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted]ធីណា សងប្រាក់ចំនួន ៤,៥០០ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិក ឱ្យទៅដើមចោទ ។

៣/ បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted]ធីណា សងសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ៣,០០០,០០០ (បីលាន) រៀល ឱ្យទៅដើមចោទ ការទាមទារលើសពីនេះច្រានចោល ។

៤/ ប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន លើប្រាក់ដើមចំនួន ៤,៥០០ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិក ។

៥/ ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃ ចន្ទ ៩រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៤ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ ។

ថ្ងៃ សុក្រ ១១កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តឧត្តរមានជ័យ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤

**ចៅក្រម**

**ហត្ថលេខា និងត្រា:** [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃ សុក្រ ១១កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តឧត្តរមានជ័យ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner